01627506

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារ **D359/17**

**តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី**
**ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម**
**ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០)

| | | |
|---|---|---|
| ចំពោះមុខ: | **ចៅក្រម ប្រាក់ គឹមសាន** | **ជាប្រធាន** |
| | **ចៅក្រម Olivier BEAUVALLET** | |
| | **ចៅក្រម ន៏យ ថុល** | |
| | **ចៅក្រម Kang Jin BAIK** | |
| | **ចៅក្រម ហួត វុទ្ធី** | |
| កាលបរិច្ឆេទ: | ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩ | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 09 / 2019
ម៉ោង (Time/Heure): 11:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ**

**សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការបន្តឋវិការបស់ក្រុមមេធាវីការពារក្តីលោក អោ អាន**

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង

Brenda HOLLIS (បម្រុង)

**<u>សហមេធាវីការពារក្តី អោ អាន</u>**

មុំ លុជ្ស

Richard ROGERS
Göran SLUITER

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ុវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARTI

National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel (855) 023 219 814 Fax (855) 023 219 841 Web www.eccc.gov.kh

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើបន្ទាន់សុំការបន្តថវិការបស់ក្រុមមេធាវីការពារក្តីលោក អោ អាន" ដែលបានដាក់ដោយសហមេធាវីការពារក្តី អោ អាន ("សហមេធាវី") នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ("សំណើបន្ទាន់")[1]។

## I. ប្រវត្តិនីតិវិធី និងអំណះអំណាង

1. នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ សហមេធាវីបានដាក់ "សំណើបន្ទាន់សុំការបន្តថវិការបស់ក្រុមមេធាវីការពារក្តីលោក អោ អាន" តែជាភាសាអង់គ្លេសប៉ុណ្ណោះ[2] ដោយស្នើសុំឲ្យអង្គបុរេជំនុំជម្រះបង្គាប់ទៅការិយាល័យរដ្ឋបាល និងអង្គភាពគាំពារការការពារក្តី ("អ.គ.ក") ឲ្យបន្តផ្តល់ថវិកាពេញលេញរបស់ក្រុមមេធាវីការពារក្តី រហូតដល់ពេលដែលអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដែលមិនទាន់សម្រេចប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ និងផ្អាកជាបន្ទាន់នូវផែនការកាត់ថវិកា ដោយរង់ចាំរហូតដល់ពេលអង្គបុរេជំនុំជម្រះសម្រេចលើសំណើបន្ទាន់នេះ[3]។ សហមេធាវីអះអាងថា សំណើបន្ទាន់របស់ខ្លួនអាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[4] ដោយសារតែការកាត់ថវិការបស់មេធាវីការពារក្តីដោយការិយាល័យរដ្ឋបាលនេះ រំលោភលើសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានការការពារក្តីប្រកបដោយប្រសិទ្ធភាព[5] ការជំនុំជម្រះឲ្យបានឆាប់រហ័ស[6] សមភាពនៃមធ្យោបាយតទល់ក្តី[7] និងភាពត្រឹមត្រូវ និងសុច្ចរិតភាពនៃកិច្ចដំណើរការនីតិវិធី[8]។ សហមេធាវីលើកទឡ្ហីករណ៍ថា អង្គបុរេជំនុំជម្រះ

---

[1] សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/២") (អបជ៦០) សំណើបន្ទាន់សុំការបន្តថវិការបស់ក្រុមមេធាវីការពារក្តីលោក អោ អាន ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D359/14 និង D360/23 ("សំណើបន្ទាន់ (ឯកសារ D359/14 និង D360/23)")។

[2] សំណើបន្ទាន់ (ឯកសារ D359/14 និង D360/23)។

[3] សំណើបន្ទាន់ (ឯកសារ D359/14 និង D360/23) កថាខណ្ឌ ៤៩។

[4] សំណើបន្ទាន់ (ឯកសារ D359/14 និង D360/23) កថាខណ្ឌ ១៩, ២១។

[5] សំណើបន្ទាន់ (ឯកសារ D359/14 និង D360/23) កថាខណ្ឌ ២៣-៣១។

[6] សំណើបន្ទាន់ (ឯកសារ D359/14 និង D360/23) កថាខណ្ឌ ៣៥-៣៨។

[7] សំណើបន្ទាន់ (ឯកសារ D359/14 និង D360/23) កថាខណ្ឌ ៣៩។

[8] សំណើបន្ទាន់ (ឯកសារ D359/14 និង D360/23) កថាខណ្ឌ ១៩។

01627508



គឺជាអង្គជំនុំជម្រះតែមួយគត់របស់ អ.វ.ត.ក ដែលបច្ចុប្បន្ននេះទទួលបានសំណុំរឿងរបស់ អោ អាន ដូច្នេះហើយអង្គបុរេជំនុំជម្រះគឺជាយន្តការដែលមានតែមួយគត់ ដែលអាចឲ្យ អោ អាន ស្វែងរកដំណោះស្រាយបាន[9]។

2. អនុលោមតាមសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩[10] សហព្រះរាជអាជ្ញាអន្តរជាតិ (បម្រុង) បានដាក់ចម្លើយតបរបស់ខ្លួននៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩[11] ហើយ អ.គ.ក បានដាក់ចម្លើយរបស់ខ្លួននៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩[12]។ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ការិយាល័យរដ្ឋបាលបានជូនដំណឹងទៅអង្គបុរេជំនុំជម្រះតាមរយៈអ៊ីម៉ែលថា ការិយាល័យរដ្ឋបាលពុំមានបំណងធ្វើការឆ្លើយតបទៅនឹងសំណើបន្ទាន់នេះទេ[13]។

3. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងសំណើបន្ទាន់នេះ អ.គ.ក អះអាងថា នៅក្នុងដំណាក់កាលនេះ ពុំមានមូលដ្ឋានសម្រាប់ឲ្យសហមេធាវីដាក់សំណើបន្ទាន់នេះទៅចំពោះមុខអង្គបុរេជំនុំជម្រះបានឡើយ ដោយហេតុថា ពុំទាន់មានសេចក្តីសម្រេចពី អ.គ.ក ដែលអាចត្រូវបានស្នើសុំឲ្យមានការពិនិត្យមើលឡើងវិញនៅឡើយទេ ដោយកត់សម្គាល់ថា សហមេធាវីពុំទាន់បានដាក់ផែនការសកម្មភាពប្រចាំខែសម្រាប់ខែកញ្ញា ឆ្នាំ២០១៩ ជូនទៅ អ.គ.ក ដើម្បីអនុម័តនៅឡើយទេ អនុលោមតាមគ្រោងការជំនួយផ្នែកច្បាប់[14]។ ហេតុនេះ អ.គ.ក សូមបញ្ជាក់ថា *សម្រាប់គោលបំណងវែកញែក* (*arguendo*) មានសេចក្តីសម្រេចផ្លូវការមួយរបស់ អ.គ.ក ដែលសម្រេចមិន

---

[9] សំណើបន្ទាន់ (ឯកសារ D359/14 និង D360/23) កថាខណ្ឌ ២០។

[10] សំណុំរឿង ០០៤/២ សេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះដល់គ្រប់ភាគី អង្គភាពគាំពារការការពារក្តី និងការិយាល័យរដ្ឋបាល អ៊ីម៉ែលចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩។

[11] សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើបន្ទាន់របស់ អោ អាន សុំការបន្តកញ្ចប់ថវិការបស់ក្រុមមេធាវីការពារក្តី ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ឯកសារ D359/15 និង D360/24។

[12] សំណុំរឿង ០០៤/២ ចម្លើយតបរបស់អង្គភាពគាំពារការការពារក្តីទៅនឹងសំណើបន្ទាន់របស់ អោ អាន សុំការបន្តកញ្ចប់ថវិការបស់ក្រុមមេធាវីការពារក្តី ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ឯកសារ D359/16 និង D360/25 ("ចម្លើយតបរបស់ អ.គ.ក (ឯកសារ D359/16 និង D360/25)")។

[13] សំណុំរឿង ០០៤/២ អ៊ីម៉ែលពីអនុប្រធានការិយាល័យរដ្ឋបាលផ្ញើជូនក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩។

[14] ចម្លើយតបរបស់ អ.គ.ក (ឯកសារ D359/16 និង D360/25) កថាខណ្ឌ ៦-៧។

បង់ប្រាក់ឈ្នួលពេញលេញដល់សហមេធាវី ហើយស្ថាប័នសមស្របដែលធ្វើការពិនិត្យមើលទៅលើសេចក្តីសម្រេចបែបនេះ គឺថៅក្រមរដ្ឋបាលរបស់អង្គការសហប្រជាជាតិ អនុលោមតាមផ្នែក ច(៩) និង (១០) នៃគ្រោងការជំនួយផ្នែកច្បាប់ និងកថាខណ្ឌ ១១ នៃកិច្ចសន្យាផ្តល់សេវាផ្នែកច្បាប់រវាងសហមេធាវី និងអង្គការសហប្រជាជាតិ[15]។

## II. **ភាពអាចទទួលយកបាន**

4. សហមេធាវីផ្អែកទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីកំណត់នូវយុត្តាធិការឥស្សរចិត្តរបស់អង្គបុរេជំនុំជម្រះ[16]។ អ.គ.ក អះអាងថា សំណើបន្ទាន់នេះមិនអាចទទួលយកបានទេ ដោយសារតែពុំទាន់មានសេចក្តីសម្រេចរបស់ អ.គ.ក ដើម្បីអាចឲ្យអង្គបុរេជំនុំជម្រះធ្វើការពិនិត្យមើលឡើងវិញនៅឡើយទេ[17]។

5. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា វិធាន ២១ នៃវិធានផ្ទៃក្នុង ការពារគោលការណ៍ជាសារវ័ន្តនៃភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក និងឆ្លុះបញ្ចាំងនូវលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលថា អ.វ.ត.ក មានកាតព្វកិច្ចត្រូវអនុវត្ត អនុលោមតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក[18] មាត្រា ៣៥ថ្មី នៃច្បាប់ អ.វ.ត.ក[19] និងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[20]។ អង្គជំនុំជម្រះបានសម្រេចថា

---

[15] ចម្លើយតបរបស់ អ.គ.ក (ឯកសារ D359/16 និង D360/25) កថាខណ្ឌ ៩។

[16] សំណើបន្ទាន់ (ឯកសារ D359/14 និង D360/23) កថាខណ្ឌ ១៩។

[17] ចម្លើយតបរបស់ អ.គ.ក (ឯកសារ D359/16 និង D360/25) កថាខណ្ឌ ៦។

[18] *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ ដែលបានចូលជាធរមាន*នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។

[19] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ នស/រកម/១០០៤/០០៦ ដោយបានធ្វើវិសោធនកម្មថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

[20] សំណុំរឿង ០០៤/០៧-០៩-អវតក/កសចស ("សំណុំរឿង ០០៤") (អបជ១៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*

*សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការបន្តថវិការបស់ក្រុមមេធាវីការពារក្តីលោក អោ អាន*

គោលការណ៍ទាំងនេះ "អាចតម្រូវឲ្យធ្វើការបកស្រាយសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ក្នុងន័យទូលាយ ដើម្បីធានាថា ដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ" ដោយទទួលយកបណ្ដឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ឬបកស្រាយយ៉ាងទូលំទូលាយនូវបទបញ្ញត្តិជាក់លាក់នៃវិធានផ្ទៃក្នុង ដែលផ្ដល់យុត្តាធិការទៅឲ្យអង្គជំនុំជម្រះ[21]។ ភាពអាចទទួលយកបានបែបនេះអាចយកមកអនុវត្ត នៅក្នុងករណីកម្រដែលអង្គហេតុពិសេសនៃរឿងក្ដីមួយលើកឡើងនូវបញ្ហាសិទ្ធិជាសារវ័ន្ត ឬបញ្ហាធ្ងន់ធ្ងរនៃភាពត្រឹមត្រូវនៃដំណើរការនីតិវិធី។

6. ទោះជាយ៉ាងណាក្ដី អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ជាបន្តបន្ទាប់ថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានផ្ដល់ការអនុញ្ញាតឲ្យប្ដឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិឡើយ ទោះបីជាបណ្ដឹងឧទ្ធរណ៍លើកឡើងនូវបញ្ហានៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ក៏ដោយ[22]។ ជាងនេះទៀត វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានអនុញ្ញាតឲ្យអង្គជំនុំជម្រះដោះស្រាយបញ្ហាជាសម្មតិកម្ម ឬផ្ដល់មតិយោបល់ណែនាំនោះទេ[23]។ ដើម្បីឲ្យអង្គបុរេជំនុំជម្រះទទួលយកបណ្ដឹងឧទ្ធរណ៍អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ម្ចាស់បណ្ដឹងឧទ្ធរណ៍ត្រូវបង្ហាញថា ស្ថានភាពដែលកំពុងពិភាក្សាមិនស្ថិតក្នុងវិធានជាធរមាននានា ហើយកាលៈទេសៈពិសេសនៃសំណុំរឿងតម្រូវឲ្យអង្គបុរេជំនុំជម្រះធ្វើអន្តរាគមន៍ដើម្បីជៀសវាងការប៉ះពាល់ *ដែលមិនអាចផ្សះផ្សារបាន* ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីស៊ើបសួរ ឬសិទ្ធិជាសារវ័ន្តរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍[24]។

---

ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ឯកសារ D239/1/8 ("សេចក្ដីពិចារណាស្ដីពីការដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* (ឯកសារ D239/1/8)") កថាខណ្ឌ ១៧។

[21] សេចក្ដីពិចារណាស្ដីពីការដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* (ឯកសារ D239/1/8) កថាខណ្ឌ ១៧។

[22] សេចក្ដីពិចារណាស្ដីពីការដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* (ឯកសារ D239/1/8) កថាខណ្ឌ ១៧។

[23] សំណុំរឿង ០០៤ (អ.ប.ជ ១៦) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ តាអាន ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ឯកសារ D208/1/1/2 កថាខណ្ឌ ៨។

[24] សេចក្ដីពិចារណាលើការសម្រេចដាក់ អ៊ឹម ចែម ក្រោមការពិនិត្យ*ដោយកំបាំងមុខ* (ឯកសារ D239/1/8) កថាខណ្ឌ ១៧។ *សូមមើលផងដែរ* សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៣") (អ.ប.ជ ២៣) សេចក្ដី

7. នៅក្នុងសំណុំរឿងនេះ សហមេធាវីអះអាងថា សំណើបន្ទាន់អាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន[25] ហើយឧបាស្រ័យនៅក្រោមផ្នែក ច (៩) និង (១០) នៃ គម្រោងជំនួយផ្នែកច្បាប់មិនបានផ្តល់ការដោះស្រាយរួម និងទាន់ពេលវេលានោះទេ[26]។

8. អង្គបុរេជំនុំជម្រះយល់ឃើញថា សហមេធាវីមិនបានបង្ហាញឱ្យបានពេញលេញនូវការសាកល្បងពីភាពអាចទទួលយកបានលើកទីមួយ ឬលើកទីពីរអនុលោមទៅតាមវិធាន ២១ នៃវិធានផ្ទៃក្នុងទេ។ ទីមួយ អង្គជំនុំជម្រះសង្កេតឃើញថា វិវាទដែលកំពុងពិភាក្សាស្ថិតក្នុងវិសាលភាពនៃនីតិវិធីនៃការដោះស្រាយវិវាទយ៉ាងត្រឹមត្រូវ អនុលោមតាមគម្រោងជំនួយផ្នែកច្បាប់ ដែលសហមេធាវីបានព្រមព្រៀងអនុវត្តកាតព្វកិច្ច[27]។ អង្គជំនុំជម្រះកត់សម្គាល់ថា អនុលោមតាមវិធាន ១១(២)(៣) និង វិធាន ១១(២)(ជ) នៃវិធានផ្ទៃក្នុង អង្គភាពគាំពារការការពារក្តីជាអ្នកពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តកិច្ចសន្យាការងាររបស់សហមេធាវីជាមួយជនជាប់ចោទ និងអនុញ្ញាតឱ្យផ្តល់ប្រាក់កម្រៃទៅតាមគម្រោងជំនួយផ្នែកច្បាប់ ជាបទបញ្ជារដ្ឋបាលមួយដែលត្រូវបានអនុម័តទៅតាមវិធាន ៤ នៃវិធានផ្ទៃក្នុង។ ហេតុនេះ អង្គជំនុំជម្រះពិចារណាឃើញថា ការធានានៅក្នុងក្របខណ្ឌគតិយុត្តិបច្ចុប្បន្នមានភាពគ្រប់គ្រាន់ ដើម្បីធានាដល់ការគោរពនូវសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន។

9. ប្រការសំខាន់ជាងនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការណ៍ដែលសហមេធាវីគ្រាន់តែប្រកាសនៅក្នុងជើងទំព័រនៃសំណើបន្ទាន់របស់ខ្លួនថា ឧបាស្រ័យដែលមានស្រាប់ចំពោះចៅក្រមរដ្ឋបាលសហប្រជាជាតិ (UNAJ) អនុលោមតាមគម្រោងជំនួយផ្នែកច្បាប់ពុំមែនជាការដោះស្រាយរួម ឬទាន់ពេលវេលា ពុំបានបង្ហាញឱ្យបានពេញលេញថា កាលៈទេសៈពិសេសនៃស្ថានភាព

---

ពិចារណាលើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ C2/4 យោបល់របស់ចៅក្រម BEAUVALLET និង BWANA កថាខណ្ឌ ៩។

[25] សំណុំបន្ទាន់ (ឯកសារ D359/14 និង D360/23) កថាខណ្ឌ ១៩ ដល់ ២១។

[26] សំណុំបន្ទាន់ (ឯកសារ D359/14 និង D360/23) កថាខណ្ឌ ១៩ ជើងទំព័រ ២២។

[27] កិច្ចសន្យាផ្តល់សេវាផ្នែកច្បាប់រវាងសហមេធាវី និងអង្គការសហប្រជាជាតិ (ភាសាអង់គ្លេស) ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ឯកសារ D359/16.1.2 និង ឯកសារ D360/25.1.2 កថាខណ្ឌ ១១។

បច្ចុប្បន្នតម្រូវឲ្យមានអន្តរាគមន៍ពីអង្គជំនុំជម្រះអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីបញ្ចៀសនូវព្យសនកម្មដែលមិនអាចផ្សះផ្សារដល់សិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន ឬភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីនោះទេ។

10. អង្គបុរេជំនុំជម្រះសូមអះអាងឡើងវិញថា អង្គជំនុំជម្រះមិនផ្តល់មតិយោបល់ណែនាំនោះឡើយ។ ក្នុងចំណុចនេះ អង្គជំនុំជម្រះសង្កេតឃើញថា សហមេធាវីមិនទាន់បានដាក់ផែនការសកម្មភាពប្រចាំខែ តារាងពេលវេលា ឬការទាមទារប្រាក់កម្រៃរបស់ខ្លួន សម្រាប់ខែកញ្ញា ឆ្នាំ២០១៩ ជូនអង្គភាពគាំពារការការពារក្តី ដើម្បីទទួលការអនុម័តទៅលើឯកសារទាំងនេះ អនុលោមតាមផ្នែក ក និង ច នៃគម្រោងជំនួយផ្នែកច្បាប់នៅឡើយទេ[28] និងបានកត់សម្គាល់ថា អង្គភាពគាំពារការការពារក្តីមិនទាន់បានចេញសេចក្តីសម្រេចលើការទាមទារប្រាក់កម្រៃពាក់ព័ន្ធនៅឡើយទេ។

11. ហេតុនេះ អង្គបុរេជំនុំជម្រះពុំជឿថា សិទ្ធិទទួលបានការការពារក្តីយ៉ាងមានប្រសិទ្ធភាព ការជំនុំជម្រះឆាប់រហ័ស សមភាពក្នុងការតទល់រឿងក្តី និង សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីនឹងទទួលរងព្យសនកម្មដែលមិនអាចផ្សះផ្សារបាន ប្រសិនបើអង្គជំនុំជម្រះមិនធ្វើអន្តរាគមន៍នៅដំណាក់កាលនេះនោះឡើយ។ ហេតុនេះ សហមេធាវីមិនបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យអំពីភាពអាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងនោះទេ។

12. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើបន្ទាន់របស់សហមេធាវីពុំអាចទទួលបានទេ ហើយអង្គជំនុំជម្រះសម្រេចបដិសេធសំណើរបស់មេធាវីការពារក្តី ដែលស្នើសុំឲ្យអង្គជំនុំជម្រះប្រើប្រាស់នូវយុត្តាធិការពីធម្មជាតិរបស់ខ្លួន ដើម្បីផ្អាកជាបន្ទាន់នូវផែនការកាត់ថវិកា រង់ចាំរហូតដល់ពេលដែលអង្គជំនុំជម្រះសម្រេចលើសំណើបន្ទាន់របស់ខ្លួន។

13. អង្គបុរេជំនុំជម្រះពិចារណាឃើញថា វាក៏ជាការពាក់ព័ន្ធដូចគ្នាដែរដែលត្រូវកត់សម្គាល់អំពីកំហុសឆ្គងនៅក្នុងការធ្វើយុត្តិកម្មរបស់អង្គភាពគាំពារការការពារក្តីចំពោះការកាត់ថវិកាដែលកំពុងពិភាក្សានេះ។ ជាពិសេស អង្គជំនុំជម្រះសង្កេតឃើញនូវអំណានដោយមិនត្រឹមត្រូវរបស់អង្គភាពគាំពារការការពារក្តី និងការលើកយកមកសំអាងដោយភាន់ច្រឡំទៅលើផែនការបញ្ចប់បច្ចុប្បន្ន។ អង្គជំនុំ

[28] *សូមមើល* គម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក វិសោធនកម្មខែធ្នូ ឆ្នាំ២០១៤ ឯកសារ D359/16.1.1 និងឯកសារ D360/25.1.1 ផ្នែក ក, ច។

ជម្រះកត់សម្គាល់ថា ពុំមែនផែនការបញ្ចប់ទេ តែជាសេចក្តីសម្រេចចុងក្រោយរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍នានាប្រឆាំងដីកាដំណោះស្រាយដែលនឹងសម្រេចថា តើសំណុំរឿង ០០៤/២ នឹងដំណើរការទៅជំនុំជម្រះ ឬយ៉ាងណានោះ។ ជាងនេះទៀត អង្គជំនុំជម្រះសង្កេតឃើញថា ផ្ទុយពីអំណានរបស់អង្គភាពគាំពារការការពារក្តី[29] ផែនការបញ្ចប់បច្ចុប្បន្នទទួលស្គាល់នូវលទ្ធភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ ទៅជំនុំជម្រះ ដូចដែលឯកសារនេះលើកឡើងថា "យើង មិនអាចស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ [ការជំនុំជម្រះក្តី] បានឡើយ" រហូតទាល់តែអង្គបុរេជំនុំជម្រះធ្វើការសម្រេចចុងក្រោយថា តើត្រូវបញ្ជូនសំណុំរឿង ០០៤/២ ទៅជំនុំជម្រះ ឬយ៉ាងណា[30]។

14. អង្គបុរេជំនុំជម្រះរម្លឹកថា កាតព្វកិច្ចរបស់អង្គភាពគាំពារការការពារក្តីអនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងការទទួលស្គាល់របស់អង្គភាពនេះផ្ទាល់ថា "មកទល់នឹងពេលនេះ ផែនការសកម្មភាព និងការទាមទារប្រាក់កម្រៃផ្លូវការទាំងអស់សម្រាប់សហមេធាវីត្រូវបានអនុម័តដោយអង្គភាពគាំពារការការពារក្តី"[31] ហេតុនេះ អង្គជំនុំជម្រះដាស់តឿនដល់អង្គភាពនេះឲ្យគិតដល់សិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ យ៉ាងយកចិត្តទុកដាក់ និងជាបន្តបន្ទាប់នៅក្នុងការធ្វើផែនការថវិកា និងការវាយតម្លៃរបស់ខ្លួន ទៅលើការទាមទារប្រាក់កម្រៃរបស់មេធាវីការពារក្តី។

## III. សេចក្តីសម្រេច

**អនុលោមតាមសំអាងហេតុទាំងនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

**មិន**ទទួលយកសំណើបន្ទាន់ទេ។

---

[29] អ៊ីមែលពីប្រធានអង្គភាពគាំពារការការពារក្តីផ្ញើជូនសហមេធាវីការពារក្តី អោ អាន ពាក់ព័ន្ធនឹងលទ្ធភាពនៃការកាត់ថវិកាចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D359/14.1.3 និងឯកសារ D360/23.1.3 កថាខណ្ឌ ៤ ("ផែនការបញ្ចប់មិនបានគិតថល់កិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅក្រោយត្រីមាសទីបួននៅឆ្នាំ២០១៩ ទេ")។

[30] ផែនការបញ្ចប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) វិសោធនកម្មលើកទី ២០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ កថាខណ្ឌ ៣៤។

[31] ចំលើយតបរបស់អង្គភាពគាំពារការការពារក្តី (ឯកសារ D359/16 និង D360/25) កថាខណ្ឌ ៨។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គីមសាន** **Olivier BEAUVALLET** **នេ យ ចុល** **Kang Jin BAIK** **ហួត វុទ្ធី**